# សុន្ទរកថា

## សម្តេចក្រឡាហោម ស ខេង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

ក្នុងពិធីបិទ

សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ គ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦

- **ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ សមាជិក សមាជិកានៃរាជរដ្ឋាភិបាល**
- **ឯកឧត្តមប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីសមាជិក សមាជិកាអង្គសិក្ខាសាលា**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងពិធីបិទសិក្ខាសាលាជាតិស្តីពី **ការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧របស់គ.ជ.អ.ប** ដែលបានប្រព្រឹត្តទៅអស់រយៈពេលពីរថ្ងៃកន្លងមកនេះ ប្រកបដោយលទ្ធផលជាផ្លែផ្កាតាមកម្មវិធីដែលបានគ្រោងទុក។ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានខិតខំប្រឹងប្រែងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៦ និងចូលរួមរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៧ដែលជាឆ្នាំចុងក្រោយនៃផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាម គ.ជ.អ.ប ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍នានាដែលបានបន្តគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ និងសូមវាយតម្លៃខ្ពស់ចំពោះអង្គការសង្គមស៊ីវិលនានាដែល

បានចូលរួមចំណែក និងផ្តល់ការគាំទ្រនៅក្នុងកិច្ចការសំខាន់ៗមួយចំនួននៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

កិច្ចខិតខំប្រឹងប្រែងជារួមរបស់យើងទាំងអស់គ្នាក្នុងការគាំទ្រ និងចូលរួមរៀបចំ និងអនុវត្តផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី១ និងផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២តាមរយៈផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប នាពេលកន្លងមកបានជំរុញឱ្យកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានការវិវត្តជឿនលឿនទៅមុខ ដោយបង្កើតបាននូវសមិទ្ធផលជាប្រវត្តិសាស្រ្តធំៗជាច្រើនពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្អែកតាមលទ្ធផលនៃការសិក្សាវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានរៀបចំឡើងដោយក្រុមទីប្រឹក្សាឯករាជ្យមួយក្រុមដែលមានការគាំទ្រពីសហភាពអឺរ៉ុប នៅក្នុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៦កន្លងមកនេះ បានបង្ហាញឱ្យឃើញថា ការអនុវត្តកម្មវិធីជាតិអស់រយៈពេលជាង៥ឆ្នាំកន្លងមកនេះ បាន និងកំពុងធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ ស្របតាមទស្សនៈវិស័យ និងគោលដៅនានានៃច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ទោះបីនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ និងមានភាពយឺតយ៉ាវក្នុងការអនុវត្តសកម្មភាពមួយចំនួន ក៏ប៉ុន្តែជាទូទៅ ក្រុមសិក្សាវាយតម្លៃបានកត់សម្គាល់ឃើញថា ក្របខ័ណ្ឌគតិយុត្តចាំបាច់នានាសម្រាប់កិច្ចដំណើរការកំណែទម្រង់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងតាមបែបប្រជាធិបតេយ្យត្រូវបានបង្កើតនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ និងកំពុងប្រតិបត្តិការដោយរលូនក្នុងស្មារតីរៀនផងអនុវត្តផង។ ធនធានហិរញ្ញវត្ថុត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចាត់ចែង និងប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិ និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការយល់ដឹងរបស់សាធារណជន និងជាពិសេសក្នុងចំណោមមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីទស្សនទាននៃកំណែទម្រង់ក៏មានការកើនឡើង។ ការងារគណនេយ្យភាពសង្គម និងការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជា

ពលរដ្ឋក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។ ទន្ទឹមគ្នានេះ ក្រុមសិក្សាវាយតម្លៃក៏បានកត់សម្គាល់ផងដែរអំពីការរីកចម្រើននៃទំនាក់ទំនង និងកិច្ចសហការកាន់តែស៊ីសង្វាក់គ្នារវាងកម្មវិធីកំណែទម្រង់សំខាន់ៗទាំង៣របស់រាជរដ្ឋាភិបាល គឺកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកត្តាចម្បងក្នុងការជំរុញឱ្យការគ្រប់គ្រងរដ្ឋបាលសាធារណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងឈានទៅសម្រេចបាននូវគោលដៅរួមនៃកម្មវិធីកំណែទម្រង់ទាំងនេះ។

ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសហភាពអឺរ៉ុបដែលបានផ្តល់ការគាំទ្រដល់ការរៀបចំការសិក្សាវាយម្លៃពាក់កណ្តាលអាណត្តិនៃកម្មវិធីជាតិនេះឡើង ដើម្បីពិនិត្យមើលលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិក្នុងរយៈពេលជាង៥ឆ្នាំកន្លងមកនេះ និងផ្តល់នូវមតិយោបល់ពាក់ព័ន្ធនឹងបញ្ហាគន្លឹះមួយចំនួនដែលមានភាពចាំបាច់ក្នុងការយកចិត្តទុកដាក់នៅក្នុងដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិ។ លទ្ធផលនៃការសិក្សាវាយតម្លៃនេះ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងទាំងក្នុងការរៀបចំ និងអនុវត្តផែនការអនុវត្តដំណាក់កាលទី៣ និងជាពិសេសសម្រាប់ការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ដែលយើងកំពុងជួបជុំគ្នារៀបចំនាពេលនេះ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

កាលពីម្សិលមិញ តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប បានធ្វើបទបង្ហាញជូនអង្គសិក្ខាសាលាអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប។ អង្គសិក្ខាសាលាក៏បានពិនិត្យ និងពិភាក្សាទៅលើបញ្ហាប្រឈមទាំងនោះ ដើម្បីស្វែងរកដំណោះស្រាយ និងវិធានការនានាសម្រាប់អនុវត្តនៅក្នុងឆ្នាំ២០១៧ខាងមុខនេះ។

ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមចូលរួមអបអរសាទរជាថ្មីម្តងទៀតចំពោះការសម្រេចបាននូវសមិទ្ធផលថ្មីៗជាច្រើនដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលជាថ្នាក់ដឹកនាំ និងជាមន្ត្រីនៃក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ថាប័នដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការគាំទ្រ និងចូលរួមចំណែក

អនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦របស់ គ.ជ.អ.ប កន្លងមកនេះ។

យ៉ាងណាមិញ យើងក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តដោះស្រាយទាំងក្នុងកម្រិតបច្ចេកទេស និងកម្រិតនយោបាយ ដែលឆ្លៀតក្នុងឱកាសនៃការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៧ ដែលជាឆ្នាំចុងក្រោយនៃផអ៣ទី២នេះ ខ្ញុំសូមផ្ដល់អនុសាសន៍ទៅលើកិច្ចការសំខាន់ៗ និងចាំបាច់មួយចំនួនដូចខាងក្រោម៖

**ទីមួយ៖ អំពីការផ្ទេរមុខងារ និងធនធាន**

ជារួម យើងបានចំណាយពេលជាច្រើនឆ្នាំមកហើយក្នុងការរៀបចំផ្ទេរមុខងារ និងធនធាន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺចាប់តាំងពីរាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ៦៨ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្ដីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការដាក់ចេញនូវគោលការណ៍ណែនាំរបស់ គ.ជ.អ.ប រួមជាមួយនឹងការសម្របសម្រួល និងគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាដល់ក្រសួង ស្ថាប័នដែលស្ថិតក្នុងវិស័យអាទិភាពក្នុងការរៀបចំកិច្ចដំណើរការផ្ទេរមុខងារ ដើម្បីធានាឱ្យមានការឯកភាពស្រុះស្រួលគ្នាទាំងក្នុងកម្រិតថ្នាក់បច្ចេកទេស និងកម្រិតនយោបាយ។

ទោះយ៉ាងនេះក្ដី ក្នុងអំឡុងពេលនៃ**ផអ៣ទី១** ពីឆ្នាំ២០១១ដល់ឆ្នាំ២០១៤ មានតែក្រសួងមួយចំនួនតូចប៉ុណ្ណោះដែលបានផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ប៉ុន្តែមុខងារដែលបានផ្ទេរទាំងនោះភាគច្រើនគឺជាការផ្ទេរនូវមុខងារតូចៗ ហើយផ្ទេរក្នុងលក្ខណៈជាការអនុវត្តសាកល្បង និងក្នុងបែបផែនជាការធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅមួយចំនួន គឺពុំមែនជាការផ្ទេរមុខងារតាមបែបផែននៃការប្រគល់ការទទួលខុសត្រូវ ដោយភ្ជាប់ជាមួយនឹងធនធានជាក់លាក់ និងភាពជាម្ចាស់ច្បាស់លាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។ អាស្រ័យហេតុនេះ **ផអ៣ទី២** បានបន្តផ្ដោតជាសំខាន់ទៅលើការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះ យើងក៏បានឯកភាពគ្នាក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប ដោយកំណត់យកឆ្នាំ២០១៥ និង២០១៦ ជាឆ្នាំដែលត្រូវមានការផ្ទេរមុខងារជាក់លាក់ និងធនធានសមស្របទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្ដល់ស្វ័យភាព និងភាពជាម្ចាស់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវា និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងការអនុវត្ត**ផអ៣ទី២**រយៈពេលជិត២ឆ្នាំកន្លងមកនេះ បើទោះបីជាក្រសួង ស្ថាប័នក្នុងវិស័យអាទិភាពបានខិតខំជំរុញកិច្ចដំណើរការផ្ទេរមុខងារនេះក៏ដោយ ក៏លទ្ធផលជាក់ស្ដែង

នៅពុំទាន់សម្រេចបានតាមការរំពឹងទុកដូចដែលបានឯកភាពគ្នាឡើយ។ ក្រសួង ស្ថាប័នមួយចំនួននៅពុំទាន់អាចកំណត់បាននូវមុខងារសមស្របសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួងមួយចំនួនផ្សេងទៀត បើទោះជាបានប្រគល់មុខងារជាក់លាក់មួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយក៏ដោយ ក៏នៅពុំទាន់អនុវត្តបានពេញលេញតាមគោលការណ៍នៃការផ្ទេរមុខងារនៅឡើយ ដោយសារមិនទាន់មានការរៀបចំប្រព័ន្ធ និងនីតិវិធីសម្រាប់គាំទ្រដល់ការអនុវត្តមុខងារទាំងនោះ រួមមានដូចជាការផ្ទេរធនធានហិរញ្ញវត្ថុ ការផ្ទេរធនធានមនុស្ស និងទ្រព្យសម្បត្តិ ការកំណត់នូវស្តង់ដារ ឬបទដ្ឋានបច្ចេកទេស និងការផ្តល់អន្តរាគមន៍គាំទ្រនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារដែលបានប្រគល់ទាំងនោះ ដែលជាហេតុធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅតែពុំមានលទ្ធភាពក្នុងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនោះបានឡើយ។ ខ្ញុំសូមលើកយកឧទាហរណ៍ជាក់ស្តែងមួយចំនួនដូចជា មុខងារគ្រប់គ្រងសំរាមនិងសំណល់រឹងទីប្រជុំជនត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក តាមរយៈអនុក្រឹត្យលេខ១១៣ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។ បើគិតមកដល់ពេលនេះ ការប្រគល់មុខងារនេះមានរយៈពេលជាង១ឆ្នាំមកហើយ ក៏ប៉ុន្តែរដ្ឋបាលក្រុង ស្រុកនៅតែពុំអាចចាប់ផ្តើមទទួលខុសត្រូវលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារគ្រប់គ្រងសំរាមនិងសំណល់រឹងទីប្រជុំជនទាំងនោះ ដោយត្រូវរង់ចាំលិខិតបទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនោះដែលត្រូវរៀបចំ និងដាក់ចេញដោយក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធនានា។ ក្នុងឆ្នាំ២០១៦នេះ មុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធក៏ត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកតាមរយៈអនុក្រឹត្យលេខ១៩១ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។ ផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ មុខងារទាំងនេះត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងចាប់ពីចុងឆ្នាំ២០១៦ និងទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅផ្សេងទៀតចាប់ពីឆ្នាំ២០១៧តទៅ។ ករណីនេះមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងការប្រគល់មុខងារគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជនដែរ។ រដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងនៅតែពុំអាចចាប់ផ្តើមគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានប្រគល់ទាំងនោះបាននៅឡើយ ពោលគឺត្រូវរង់ចាំការដាក់ចេញនូវលិខិតបទដ្ឋាន បែបបទ និងនីតិវិធីការផ្ទេរធនធានហិរញ្ញវត្ថុ ការផ្ទេរបុគ្គលិក និងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារទាំងនោះ។ និយាយឱ្យខ្លី គឺយើងបានប្រគល់មុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតែនៅលើក្រដាស។

ទាំងនេះជាមេរៀន និងបទពិសោធន៍ដែលយើងត្រូវរួមគ្នាដោះស្រាយ និងកែលម្អ។

ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំសូមស្នើឱ្យក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងមហាផ្ទៃត្រូវសហការគ្នាដើម្បីពន្លឿនដល់ការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនានា និង ផ្ដល់អន្តរាគមន៍គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ ដែលបានប្រគល់ទាំងនោះឱ្យបានចាប់ពីដើមឆ្នាំ២០១៧នេះតទៅ។ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈត្រូវសហការជាមួយក្រសួង ស្ថាប័នផ្ទេរមុខងារ និងរដ្ឋ បាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិសម្រាប់អនុវត្តមុខងារនានាដែលបានប្រគល់ទាំងនោះឱ្យបាននៅចុងឆ្នាំនេះ។ ជាការពិតណាស់ អនុក្រឹត្យស្ដីពីការប្រគល់មុខងារទាំងនេះបានផ្ដល់នូវពេលវេលាអន្តរកាល សម្រាប់ការរៀបចំលិខិតបទដ្ឋាន និងកិច្ចការចាំបាច់នានាមុននឹងឈានទៅដល់ការអនុវត្ត ពេញលេញតាមល័ក្ខខ័ណ្ឌ និងគោលការណ៍នានានៃការប្រគល់មុខងារ ក៏ប៉ុន្តែយើងក៏មិនត្រូវ អូសបន្លាយពេលវេលាអន្តរកាលនេះឱ្យវែងពេកនោះទេ។

ក្រៅពីនេះ ខ្ញុំសូមស្នើឱ្យក្រសួង ស្ថាប័នដែលស្ថិតក្នុងវិស័យអាទិភាពផ្សេងទៀតបន្តកិច្ច ខិតខំប្រឹងប្រែងក្នុងការជំរុញកិច្ចដំណើរការផ្ទេរមុខងាររបស់ខ្លួន ដើម្បីឈានទៅធ្វើការសម្រេច ចិត្តក្នុងការកំណត់ និងផ្ទេរនូវមុខងារសំខាន់ៗផ្សេងទៀត ជាពិសេសមុខងារពាក់ព័ន្ធនឹងវិស័យ សុខាភិបាល កសិកម្ម ធនធានធម្មជាតិ ព្រៃឈើ ជលផល ធនធានទឹក សាធារណការ និង សង្គមកិច្ចជាដើម ដែលជាកិច្ចការដ៏មានសារៈសំខាន់ និងជាកិច្ចការដែលចាំបាច់តម្រូវឱ្យមាន ការចូលរួមចំណែក និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅ គ្រប់លំដាប់ថ្នាក់។ នាពេលថ្មីៗនេះ គ.ជ.អ.ប បានទទួលគោលការណ៍ពី **សម្ដេចតេជោ នាយក រដ្ឋមន្ត្រី** ក្នុងការជំរុញឱ្យក្រសួង ស្ថាប័ននានារៀបចំបញ្ជីមុខងារដែលត្រូវស្នើផ្ទេរទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តពិភាក្សា សម្រប សម្រួលជាមួយក្រសួង ស្ថាប័ននានាក្នុងវិស័យទាំងនេះ ដើម្បីរៀបចំបញ្ជីមុខងារដែលសម ស្របនានាដើម្បីដាក់ឆ្លងកិច្ចប្រជុំ គ.ជ.អ.ប ដែលគ្រោងរៀបចំនៅចុងឆ្នាំនេះ និងស្នើសុំការ សម្រេចពីប្រមុខ រាជរដ្ឋាភិបាលតែម្ដង។

**ទីពីរៈ អំពីវិមជ្ឈការហិរញ្ញវត្ថុ**

គោលបំណងសំខាន់នៃវិមជ្ឈការហិរញ្ញវត្ថុ គឺដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមាន ប្រភពធនធានហិរញ្ញវត្ថុ មានប្រព័ន្ធ មាននីតិវិធី និងមានសមត្ថភាពក្នុងការគ្រប់គ្រង ការចាត់

ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ពាក់ព័ន្ធនឹងការងារនេះ **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុន្នីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** បានគូសបញ្ជាក់នៅក្នុងសុន្ទរកថាបើកសិក្ខាសាលាជាតិកាលពីម្សិលមិញរួចហើយ អំពីការវិវត្តនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិធានការចាំបាច់នានាដើម្បីបន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។ ខ្ញុំសូមឯកភាពទាំងស្រុងទៅលើផែនការសកម្មភាពសំខាន់ៗដែលបានលើកឡើងពាក់ព័ន្ធនឹងការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ និងការបង្កើនមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក ការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ ការអនុវត្តយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការផ្តល់អាទិភាពទៅលើការធ្វើវិមជ្ឈការហិរញ្ញវត្ថុនៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងធានាបាននូវភាពសុខដុមនីយកម្មរវាងកម្មវិធីកំណែទម្រង់ទាំង២ ពោលគឺកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាពិសេសនឹងធានាបាននូវភាពប្រទាក់ក្រឡាគ្នារវាងការផ្ទេរមុខងារ និងការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចាប់ពីដើមឆ្នាំ២០១៧តទៅ។

បន្ថែមលើនេះ ខ្ញុំស្នើក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសិក្សាអំពីលទ្ធភាពដើម្បីបង្កើនទំហំធនធាននៃមូលនិធិក្រុង ស្រុក ជាពិសេសធនធានសម្រាប់ផ្នែកអភិវឌ្ឍមូលដ្ឋានឱ្យមានចំនួនសមស្របសម្រាប់ឱ្យរដ្ឋបាលក្រុង ស្រុកប្រើប្រាស់ក្នុងការរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋាននានាដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាជននៅក្នុងមូលដ្ឋានរបស់ខ្លួន។ ជាការពិតណាស់ ទោះបីរាជរដ្ឋាភិបាលបានបង្កើនជាបន្តបន្ទាប់នូវអត្រានៃការផ្ទេរធនធានថវិការជួទៅឱ្យមូលនិធិក្រុង ស្រុក ពី0,៨% ទៅ 0,៩% និងឈានទៅដល់១%នៃចំណូលចរន្តថវិកាជាតិប្រចាំឆ្នាំចាប់ពីឆ្នាំ២០១៧ខាងមុខនេះក៏ដោយ ប៉ុន្តែដោយសារតែការកើនឡើងនូវប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ប្រើប្រាស់មូលនិធិក្រុង ស្រុកនេះស្ទើរតែទាំងស្រុងសម្រាប់រ៉ាប់រងតែទៅលើការចំណាយលើប្រាក់ បៀវត្សទាំងនេះ និងចំណាយសម្រាប់កិច្ចការរដ្ឋបាលតែប៉ុណ្ណោះ។ ជារួម រដ្ឋបាលក្រុង ស្រុកមានមូលនិធិដែលនៅសេសសល់តិចតួចប៉ុណ្ណោះសម្រាប់គម្រោង

អភិវឌ្ឍមូលដ្ឋាន និងសម្រាប់ការផ្តួចផ្តើមគំនិតក្នុងការអនុវត្តមុខងារចាំបាច់នានាដែលក្រសួង ស្ថាប័នពុំបានអនុវត្ត ប៉ុន្តែជាមុខងារសម្រាប់ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់មូលដ្ឋាន។ អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគប្បីសិក្សាលទ្ធភាពនានាដើម្បីស្នើទៅរាជរដ្ឋាភិបាលក្នុងការបង្កើនទំហំនៃមូលនិធិក្រុង ស្រុកក្នុងអត្រាសមស្របមួយធៀបនឹងចំណូលចរន្តថវិកាជាតិប្រចាំឆ្នាំ ដើម្បីបង្កើនធនធានផ្នែកអភិវឌ្ឍមូលដ្ឋានឱ្យបានដល់អត្រា ០,៥%ធៀបទៅនឹងចំណូលចរន្តថវិកាជាតិប្រចាំឆ្នាំចាប់ពីឆ្នាំ២០១៩តទៅ ដូចដែលយើងបានកំណត់ និងឯកភាពគ្នាក្នុងផអ៣ទី២។

**ទីបី៖ អំពីការអភិវឌ្ឍស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ**

ការបន្តពង្រឹងការអភិវឌ្ឍស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជារដ្ឋបាលដ៏រឹងមាំ មានបែបផែនគ្រប់គ្រងតាមគោលការណ៍រដ្ឋបាលឯកភាព មានថាមភាព និងមានលទ្ធភាពទទួលខុសត្រូវយ៉ាងពេញលេញក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តនូវមុខងារ និងធនធាននានាដែលបានផ្ទេរឱ្យ ក៏នៅតែជាចំណុចដៅជាអាទិភាពដ៏មានសារៈសំខាន់មួយដែលយើងត្រូវបន្តខិតខំសម្រេចឱ្យបាននៅក្នុងឆ្នាំ២០១៧។

ពាក់ព័ន្ធនឹងកិច្ចការនេះ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃត្រូវបន្តផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាបន្ថែមទៀតក្នុងកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាដើម្បីបន្តពង្រឹងការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលក្នុងនោះ រួមមានការពិនិត្យមើលឡើងវិញអំពីប្រសិទ្ធភាពនៃរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីការងារដែលកំពុងអនុវត្តបច្ចុប្បន្ន ព្រមទាំងផ្តល់អន្តរាគមន៍ជាសំខាន់ទៅលើការលើកកម្ពស់សមត្ថភាពស្ថាប័ន និងធនធានមនុស្សរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ដើម្បីធានាថារដ្ឋបាលទាំងនេះមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ចាត់ចែងការផ្តល់សេវានានាដែលបានផ្ទេរទៅឱ្យនាពេលកន្លងមក និងដែលគ្រោងផ្ទេរបន្ថែមទៀតចាប់ពីដើមឆ្នាំ២០១៧តទៅ។

នាពេលថ្មីៗកន្លងមកនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ១៩២ស្តីពីការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្នុងគោលបំណងរៀបចំឱ្យមានយន្តការច្បាស់លាស់ដែលធានាដល់ប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការ សមាជិកក្រុមប្រឹក្សារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងចូលរួមចំណែកដ៏សំខាន់ក្នុងការសិក្សាស្រាវជ្រាវវាយតម្លៃដើម្បីកែលម្អគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងកំណែទម្រង់ការ

អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ដើម្បីធានាដល់ការចាប់ផ្តើមរៀបចំបង្កើត និងការប្រព្រឹត្តទៅនៃសាលាជាតិរដ្ឋបាលមូលដ្ឋាននេះ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការសិក្សា និងរៀបចំផែនការមេឱ្យបានច្បាស់លាស់មួយនៅក្នុងឆ្នាំ២០១៧នេះ ដើម្បីធ្វើផែនទីបង្ហាញផ្លូវសម្រាប់ការរៀបចំហេដ្ឋា រចនាសម្ព័ន្ធរូបវន្ត រចនាសម្ព័ន្ធគ្រប់គ្រង ការរៀបចំកម្មវិធីសិក្សា និងការគ្រប់គ្រងកិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាននេះ។

ពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមុខងារសាធារណៈត្រូវជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាសម្រាប់អនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនឹងចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧នេះតទៅ ដើម្បីធានាដល់ការលើកកម្ពស់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួន សំដៅលើកកម្ពស់គណនេយ្យភាពរបស់បុគ្គលិកចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និងបង្កលក្ខណៈងាយស្រួលក្នុងការផ្ទេរការគ្រប់គ្រងបុគ្គលិកភ្ជាប់ជាមួយនឹងការផ្ទេរមុខងារនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តពង្រឹងការគ្រប់គ្រង ការចាត់ចែងមន្ត្រីឱ្យបំពេញការងារតាមបែបបទ និងនីតិវិធីអនុវត្តការងារដែលបានកំណត់ ដោយត្រូវមានការត្រួតពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ។ ជាមួយគ្នានេះ ចាំបាច់ត្រូវបន្តពង្រឹងការរៀបចំល័ក្ខខ័ណ្ឌការងាររបស់មន្ត្រីម្នាក់ៗឱ្យបានច្បាស់លាស់ និងត្រូវធានាដល់ការប្រគល់តួនាទី ភារកិច្ចដល់មន្ត្រី និងអង្គភាពឱ្យស្របតាមជំនាញ និងល័ក្ខខ័ណ្ឌការងារ ព្រមទាំងត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អំពីក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌនៃការអនុវត្តកំណែទម្រង់ និងជំនាញជាក់លាក់របស់មន្ត្រីនានាដែលបំពេញការងារក្នុងមុខដំណែងតាមអង្គភាពនីមួយៗ ដោយត្រូវគ្រោងកញ្ចប់ថវិការាជធានី ខេត្តរបស់ខ្លួនឱ្យបានច្បាស់លាស់សម្រាប់គាំទ្រដល់សកម្មភាពអភិវឌ្ឍសមត្ថភាពទាំងនេះ។

**ទីបួន៖ អំពីការធ្វើអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

នៅពេលដែលមុខងារ និងធនធានត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងស្ថាប័ននៅថ្នាក់ជាតិក្រៅពីមានតួនាទីក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋាន ស្តង់ដារបច្ចេកទេស និងផ្តល់អន្តរាគមន៍គាំទ្រ ក៏មានតួនាទីនិងសិទ្ធិអំណាចសំខាន់មួយផ្សេងទៀត គឺ

ការធ្វើអធិការកិច្ចដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិបានគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវក្នុងការអនុវត្តនូវមុខងារ និងធនធានដែលបានផ្ទេរទាំងនោះ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធ នីតិវិធីនិងស្តង់ដារនានាដែលបានកំណត់។ ជាទូទៅ ការធ្វើអធិការកិច្ចមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវ និងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជំរុញដល់ការលើកកម្ពស់អភិបាលកិច្ចល្អ និងទប់ស្កាត់ភាពមិនត្រឹមត្រូវនៃការប្រើប្រាស់ធនធានសាធារណៈ។

ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធអធិការកិច្ចនេះ គឺជាលទ្ធផលរំពឹងទុកដ៏មានសារៈសំខាន់មួយនៃផអ៣ទី២។ ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ក្រសួងមហាផ្ទៃត្រូវបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំលិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីនីតិវិធីធ្វើអធិការកិច្ច ដើម្បីធានាដល់ការចាប់ផ្តើមអនុវត្តការធ្វើអធិការកិច្ចទៅលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងឆ្នាំ២០១៧នេះ។

**ទីប្រាំ៖ អំពីការងារគណនេយ្យភាពសង្គម**

ការបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋឱ្យទទួលបាននូវព័ត៌មានសំខាន់ៗអំពីការប្រើប្រាស់ថវិកា និងការផ្តល់សេវារបស់រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពផ្តល់សេវានៅមូលដ្ឋានមួយចំនួន ដូចជាសាលារៀន និងមណ្ឌលសុខភាព ព្រមទាំងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការតាមដានត្រួតពិនិត្យលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន គឺជាផែនការយុទ្ធសាស្ត្រដ៏សំខាន់នៃការងារគណនេយ្យភាពសង្គម និងជាសារធាតុជាគន្លឹះនៃអភិបាលកិច្ចមូលដ្ឋាន ដើម្បីចូលរួមចំណែកពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ក្នុងឆ្នាំ២០១៦នេះ ដោយមានការគាំទ្រ និងចូលរួមយ៉ាងសកម្មពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ព្រមទាំងអង្គការសង្គមស៊ីវិលមួយចំនួនបានធ្វើឱ្យការងារគណនេយ្យភាពសង្គមនេះត្រូវបានអនុវត្តនៅតាមក្រុង ស្រុកគោលដៅមួយចំនួនប្រកបដោយភាពរលូន និងទទួលបានលទ្ធផលគួរជាទីមោទនៈ។ ក្នុងឆ្នាំ២០១៧ខាងមុខនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តខិតខំសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា អង្គការសង្គមស៊ីវិលជាដៃគូ ដើម្បីបន្តពង្រីកការអនុវត្តការងារគណនេយ្យភាពសង្គមនេះទៅតាមឃុំ សង្កាត់នានាក្នុងក្រុង ស្រុកគោលដៅមួយចំនួនផ្សេងទៀត ដោយផ្អែកលើមេរៀន និងបទពិសោធន៍ដែលបានអនុវត្តនាពេលកន្លងមក។

**ទីប្រាំមួយ៖ អំពីការបន្តលើកកម្ពស់ការងារយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម**

ផអ៣ទី២ បានបន្តផ្តោតការយកចិត្តទុកដាក់ឱ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀតទៅលើការបញ្ជ្រាបយេនឌ័រ ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម ដើម្បីធានានូវការផ្តល់សិទ្ធិដល់ក្រុមផ្សេងៗ ជាពិសេសក្រុមជនងាយរងគ្រោះ និងក្រុមជនក្រីក្រឱ្យទទួលបានឱកាសសមស្របក្នុងការចូលរួម និងទទួលបានផលប្រយោជន៍ដោយមិនរើសអើងពីការផ្តល់សេវា និងពីការអភិវឌ្ឍមូលដ្ឋាន។ នេះគឺជាល័ក្ខខ័ណ្ឌដ៏ចាំបាច់មួយនៅក្នុងការរៀបចំធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយនៅតាមមូលដ្ឋាននីមួយៗ។ ផអ៣ទី២ ក៏បានកំណត់នូវវិធានការ និងជម្រើសនានាដើម្បីធានាដល់ការបញ្ជ្រាបយេនឌ័រ លើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងលទ្ធផលរំពឹងទុកទាំងអស់។ ពាក់ព័ន្ធនឹងកិច្ចការនេះ ខ្ញុំសូមស្នើក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប បន្តការសម្របសម្រួល និងគាំទ្រក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំបញ្ជ្រាបកិច្ចការដ៏មានសារៈសំខាន់នេះទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ស្ថាប័នដើម្បីធានាឱ្យបានថា រាល់ការធ្វើសេចក្តីសម្រេចចិត្តនានាទៅលើការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងថវិកានានារបស់ស្ថាប័ននីមួយៗត្រូវបានគិតគូរ យកចិត្តទុកដាក់អំពីការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីត្រូវផ្តល់អាទិភាពទៅលើការរៀបចំ និងដាក់ចេញនូវយុទ្ធសាស្ត្រជាក់លាក់ដើម្បីបង្កើនចំនួនស្ត្រីក្នុងមុខដំណែងនានា ជាពិសេសក្នុងមុខដំណែងដែលមានតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ខ្ញុំសូមឱ្យថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិចាត់ទុកកិច្ចការនេះជាអាទិភាពមួយនៅក្នុងដឹកនាំ គ្រប់គ្រង និងចាត់ចែងការងារនៅក្នុងស្ថាប័នរបស់ខ្លួន ដើម្បីធានាដល់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមមូលដ្ឋានប្រកបដោយសុខដុមរមនានៅក្នុងសង្គម។

**ទីប្រាំពីរ៖ ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មាន**

ការធ្វើឱ្យមានភាពល្អប្រសើរឡើងក្នុងការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានឱ្យបានទូលំទូលាយ និងទាន់ពេលវេលាអំពីចក្ខុវិស័យ អំពីក្របខ័ណ្ឌច្បាប់ និងអំពីក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់ជាទូទៅក្នុងចំណោមសាធារណជន ជាពិសេសរវាងតួអង្គប្រតិបត្តិពាក់ព័ន្ធនានា គឺជាកត្តាដ៏មានសារៈសំខាន់នៃការធ្វើឱ្យមានការចូលរួមចំណែកកាន់តែទូលំទូលាយ និងកាន់តែសកម្មនៅក្នុងកិច្ចដំណើរការកំណែទម្រង់របស់យើង។ នាពេលកន្លងមក

ទោះបីជាមានការដាក់ចេញនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាជាច្រើនក្តី ក៏ការយល់ដឹងរបស់មន្ត្រីភាគច្រើនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាសាធារណជននៅតែពុំទាន់មានលក្ខណៈស៊ីជម្រៅអំពីកំណែទម្រង់នៅឡើយ។

អាស្រ័យហេតុនេះ ក្នុងឆ្នាំ២០១៧ខាងមុខនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបង្កើនការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាបន្ថែមទៀតទៅលើការពង្រឹងយន្តការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មាននេះ ដោយត្រូវពិនិត្យមើលឡើងវិញ និងកែសម្រួលនូវយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដើម្បីបង្កើតជាឧបករណ៍ មធ្យោបាយ សម្ភារៈចាំបាច់នានាដែលធានាដល់ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានឱ្យមានលក្ខណៈកាន់តែខ្លី សាមញ្ញតែងាយយល់ និងប្រកបដោយទំនើបកម្ម និងត្រូវជំរុញការអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនេះឱ្យបានទូលំទូលាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងឱ្យមានការចូលរួមពីអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។

**ទីប្រាំបី៖ កិច្ចសហការរវាងកម្មវិធីកំណែទម្រង់ស្នូលទាំង៣**

កំណែទម្រង់ស្នូលទាំង៣ ពោលគឺកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកំណែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ និងមានគោលបំណងរួមតែមួយ គឺការលើកកម្ពស់អភិបាលកិច្ចល្អនៃស្ថាប័នសាធារណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅបង្កើនប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន។

កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផ្តោតទៅលើការផ្ទេរសិទ្ធិអំណាច និងផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសំដៅបង្កិតការធ្វើសេចក្តីសម្រេចចិត្តលើការប្រើប្រាស់ធនធានសាធារណៈសម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍឱ្យទៅកៀកជិត និងមានគណនេយ្យភាពផ្ទាល់ជាមួយប្រជាពលរដ្ឋ។ កំណែទម្រង់រដ្ឋបាលសាធារណៈ ផ្តោតទៅលើការលើកកម្ពស់ប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងមន្ត្រីសាធារណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីប្រែក្លាយមន្ត្រីសាធារណៈឱ្យក្លាយជាមន្ត្រីដែលប្រកបដោយសីលធម៌ និងមានវិជ្ជាជីវៈច្បាស់លាស់ក្នុងការបម្រើ និងផ្តល់សេវាសាធារណៈនានាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្តោតទៅលើការកែលម្អប្រព័ន្ធថវិកា ដើម្បីធានាទាំងការប្រមូលចំណូល និងការចំណាយធនធានសាធារណៈ

ឆ្លើយតបទៅនឹងគោលនយោបាយ គោលបំណង និងលទ្ធផលរំពឹងទុករបស់ស្ថាប័នសាធារណៈគ្រប់ថ្នាក់។ ក្នុងន័យនេះ កំណែទម្រង់ស្នូលទាំង៣នេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តឱ្យមានភាពស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នា ទើបអាចធានាដល់ការសម្រេចបាននូវគោលបំណងរួមរបស់កំណែទម្រង់ទាំង៣។

អាស្រ័យហេតុនេះ លេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់ស្នូលទាំង៣ត្រូវខិតខំបន្តកិច្ចសហការគ្នាឱ្យកាន់តែជិតស្និទ្ធបន្ថែមទៀត តាមរយៈការរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាគ្នាជាប់ជាប្រចាំ និងរៀបចំជាផែនការរួមមួយសម្រាប់កិច្ចការនានាដែលមានភាពប្រទាក់ក្រឡាគ្នារវាងកំណែទម្រង់ទាំង៣ ដើម្បីធានាសង្គតិភាព និងប្រសិទ្ធភាពនៃការអនុវត្តកំណែទម្រង់ទាំងនេះ។

**ទីប្រាំបួន៖ ការរៀបចំផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី៣**

ដូចខ្ញុំបានគូសបញ្ជាក់ពីខាងដើមថា ឆ្នាំ២០១៧គឺជាឆ្នាំចុងក្រោយនៃ**ផអ៣ទី២**។ ដើម្បីធានាដល់ការអនុវត្តដំណាក់កាលសេសសល់ចុងក្រោយនៃកម្មវិធីជាតិ តម្រូវឱ្យមានការចាប់ផ្តើមរៀបចំផែនការអនុវត្តដំណាក់កាលទី៣ក្នុងឆ្នាំ២០១៧ខាងមុខនេះ។ ក៏ប៉ុន្តែ ដោយសារកម្មវិធីជាតិរយៈពេល១០ឆ្នាំរបស់យើងនឹងត្រូវបញ្ចប់នៅឆ្នាំ២០១៩ ដូច្នេះផែនការអនុវត្តដំណាក់កាលទី៣នៃកម្មវិធីជាតិនេះអាចមានរយៈពេល២ឆ្នាំ គឺឆ្នាំ២០១៨ និងឆ្នាំ២០១៩។ ទោះយ៉ាងនេះក្តី យើងអាចពិចារណាទៅលើការពន្យារពេលនៃការអនុវត្តកម្មវិធីជាតិ រយៈពេល១ឆ្នាំបន្ថែមទៀត ដើម្បីធានាឱ្យយើងមានពេលវេលាគ្រប់គ្រាន់ក្នុងការសម្រេចគោលដៅនានារបស់កម្មវិធីជាតិ។ យើងនឹងលើកយកបញ្ហានេះទៅពិនិត្យ និងពិភាក្សាក្នុងកិច្ចប្រជុំ គ.ជ.អ.ប នាពេលខាងមុខនេះ ដើម្បីធ្វើជាមូលដ្ឋានក្នុងការចាប់ផ្តើមរៀបចំផែនការអនុវត្តដំណាក់កាលទី៣នៃកម្មវិធីជាតិនេះឱ្យ បានរួចរាល់នៅមុនបំណាច់ឆ្នាំ២០១៧។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ជាទូទៅកំណែទម្រង់វិមជ្ឈការគឺជាកំណែទម្រង់ដែលមានលក្ខណៈស្មុគស្មាញ សាំញ៉ាំ និងត្រូវអនុវត្តដោយប្រុងប្រយ័ត្ន មានការសម្របសម្រួល និងប្រកបដោយសនិទានភាពផ្អែកលើបរិបទប្រវត្តិសាស្ត្រ នយោបាយ សង្គម សេដ្ឋកិច្ចជាក់ស្តែងរបស់ប្រទេសកម្ពុជាយើង។ កំណែទម្រង់នេះមានផលប៉ះពាល់ទាំងផ្នែកនយោបាយ និងផ្នែករដ្ឋបាលរបស់ស្ថាប័នទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី កំណែទម្រង់នេះនៅតែជាជម្រើសដ៏ល្អនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈដែលបណ្តាប្រទេសជាច្រើននៅលើសកល

លោកកំពុងប្រកាន់យកនាពេលបច្ចុប្បន្ននេះ។ សម្រាប់កម្ពុជា រាជរដ្ឋាភិបាលមានការតាំងចិត្តផ្នែកនយោបាយយ៉ាងច្បាស់លាស់អំពីការអនុវត្តកំណែទម្រង់នេះ ដើម្បីធានាដល់ការឆ្លើយតបទៅនឹងការរីកចម្រើនរបស់សង្គមដែលធ្វើឱ្យមានការកើនឡើងនូវតម្រូវការនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកដដោយលក្ខណៈឆ្លើយតប និងកាន់តែទូលំទូលាយបន្ថែមទៀតជូនប្រជាពលរដ្ឋ។

ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នេះ យើងនៅតែត្រូវការការគាំទ្រដ៏ចាំបាច់ពីដៃគូអភិវឌ្ឍន៍នានាក្នុងរយៈពេលមធ្យមមួយបន្ថែមទៀតដើម្បីធានាដល់ការឈានឆ្ពោះទៅសម្រេចគោលបំណងចុងក្រោយនៃកំណែទម្រង់។ ជំនួសមុខឱ្យប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបាន និងកំពុងបន្តផ្តល់ការគាំទ្រប្រកបដោយភាពយោគយល់ដល់កិច្ចដំណើរការកំណែទម្រង់នៅកម្ពុជា។ ខ្ញុំសូមធានាអះអាងថា ជំនួយទាំងនេះនឹងត្រូវបានប្រើប្រាស់ប្រកបដោយគណនេយ្យភាព និងតម្លាភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែកយ៉ាងសកម្មរបស់អង្គការសង្គមស៊ីវិលនានានៅក្នុងកិច្ចដំណើរការជាទូទៅនៃកំណែទម្រង់ដ៏មានសារៈសំខាន់នេះ និងសូមលើកទឹកចិត្តឱ្យមានការបន្តកិច្ចសហការដ៏ល្អទាំងនេះជាបន្តទៅទៀត។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួម និងផ្តល់មតិយោបល់ក្នុងសិក្ខាសាលាជាតិរយៈពេលពីរថ្ងៃនេះ និងសូមថ្លែងអំណរគុណដល់លេខាធិការ ដ្ឋាន គ.ជ.អ.ប ដែលបានខិតខំប្រឹងប្រែងរៀបចំ និងសម្របសម្រួលរាល់កិច្ចការដែលធ្វើឱ្យសិក្ខាសាលាទទួលបានលទ្ធផលជាផ្លែផ្កាតាមការគ្រោងទុក។

ជាទីបញ្ចប់ ជាមួយសមិទ្ធផលដែលសម្រេចបានក្នុងសិក្ខាសាលាជាតិនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ និង**សូមប្រកាសបិទសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។**

**សូមអរគុណ៕**